ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

មន្ទីរ ដ.ន.ស.ស ខេត្តកំពង់ធំ

លេខ:.......................

# សេចក្តីប្រកាសព័ត៌មាន

**ឆ្លើយតបនឹងការចុះផ្សាយព័ត៌មាន របស់ហ្វេសបុកផេកឈ្មោះ Horn News នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ ដែលបានលើកឡើងជាខ្លឹមសារថា "ប្រជាពលរដ្ឋបានលើកឡើងថាឈូសឆាយដីដំណាំរបស់គាត់យកទៅចែកឱ្យអ្នកផ្សេង ធ្វើឱ្យគាត់មិនអាចទទួលយកបាននោះទេ អ្វីដែលប្រជាពលរដ្ឋឆ្ងល់ថាក្នុងក្រសួងដែនដីដែលប្រកាសគឺ នៅឃុំគោល និង ឃុំទីរឹង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ហេតុអ្វីមកឈូសឆាយដីដំណាំប្រជាពលរដ្ឋនៅភូមិថ្មី ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំទៅវិញ"**

---

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ** សូមជម្រាបជូនដំណឹងដល់សាធារណៈជនទាំងអស់ឱ្យបានជ្រាបថា÷ កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ ហ្វេសបុកផេកឈ្មោះ Horn News បានផ្សព្វផ្សាយព័ត៌មានដែលបានលើកឡើងជាខ្លឹមសារថា "ប្រជាពលរដ្ឋបានលើកឡើងថាឈូសឆាយដីដំណាំរបស់គាត់យកទៅចែកឱ្យអ្នកផ្សេងធ្វើឱ្យគាត់មិនអាចទទួលយកបាននោះទេ អ្វីដែលប្រជាពលរដ្ឋឆ្ងល់ថាក្នុងក្រសួងដែនដីដែលប្រកាសគឺ នៅឃុំគោល និង ឃុំទីរឹង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ហេតុអ្វីមកឈូសឆាយដីដំណាំប្រជាពលរដ្ឋនៅភូមិថ្មី ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំទៅវិញ" ។

ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មាន របស់ហ្វេកបុកផេកឈ្មោះ Horn News ដូចរៀបរាប់ខាងលើ  មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ សូមធ្វើការបំភ្លឺដូចខាងក្រោម÷

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) ជាគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា  ដែលគាំទ្រដោយធនាគារពិភពលោក បានចូលជាធរមាននៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០២០ រយៈពេល ៦ឆ្នាំ ចាប់ពីឆ្នាំ២០២០ ដល់ ឆ្នាំ២០២៦ ។ គម្រោង LASED III ត្រូវបានអនុវត្ត ដោយផ្អែកលើកម្មវិធីសម្បទានដីសង្គមកិច្ច អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច និងប្រកាសលេខ ២០០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីគោលការណ៍ណែនាំអនុវត្តន៍អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ គម្រោង LASED III ត្រូវបានបង្កើតឡើងក្នុងគោលបំណងបែងចែកដីសម្បទានដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រ ដែលគ្មានដី ឬ មានដីតិចតួច ដើម្បីលើកកម្ពស់ជីវភាពរបស់ពួកគាត់ តាមរយៈការអភិវឌ្ឍ និងកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត និងការលើកកម្ពស់ការប្រកបមុខរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។

ជាមួយគ្នានេះ ទីតាំងដីឃុំទីវីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ បានទទួលសេចក្ដីសម្រេចពីរាជរដ្ឋាភិបាល លើផ្ទៃដីទំហំ ៨៧១ ហិកតា ស្ថិតនៅភូមិក្បាលដំរី ឃុំទីវីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣(អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២) ហើយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ បានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 06060905-0001 ក្បាលដីលេខ 1 ផ្ទៃដីទំហំ ៨៧១.១១៧០ហិកតា (ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣) ដើម្បីផ្ដល់លទ្ធភាពរៀបចំផែនការប្រើប្រាស់ដីលម្អិតក្នុងទីតាំងសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋានឃុំទីវីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។ គម្រោង LASED III ដឹកនាំអនុវត្តន៍ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាស្ថាប័នដឹកនាំគម្រោង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាស្ថាប័នអនុវត្តន៍គម្រោង រួមទាំងរដ្ឋបាលខេត្ត មន្ទីរជំនាញពាក់ព័ន្ធ រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ ។

<u>**សូមបញ្ជាក់ថា ទីតាំងដីអនុវត្តន៍គម្រោង LASED III គឺ ស្ថិតនៅក្នុងឃុំទីវីង ស្រុកសណ្ដាន់ មិនមែនស្ថិតនៅក្នុងឃុំស្រើង ស្រុកប្រាសាទសំបូរ ដូចការលើកឡើងរបស់ប្រជាពលរដ្ឋនោះទេ។ ជាមួយគ្នា រដ្ឋបាលខេត្តកំពង់ធំ បានធ្វើសិក្សាផលប៉ះពាល់លម្អិតលើទីតាំងដី មុននឹងស្នើសុំអនុបយោគពីរាជរដ្ឋាភិបាល ដើម្បីអនុវត្តន៍គម្រោងនេះ។**</u>

ក្រុមការងារគម្រោង LASED III ខេត្តកំពង់ធំ បានអនុវត្តដំណើរការសម្បទានដីសង្គមកិច្ច ឃុំទីវីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ទាំង១០ជំហាន ដែលមាន÷ ១. ការចាប់ផ្ដើម និងពិនិត្យលើដីសម្បទានសង្គមកិច្ច, ២. ការសិក្សាផែនការបច្ចេកទេស, ៣. ការលើកកម្ពស់ការយល់ដឹង, ៤. ការគូសផែនទីដីរដ្ឋ, ៥. ការរៀបចំផែនការតាមបែបចូលរួម, ៦. ការពិនិត្យឡើងវិញលើរបាយការណ៍ដីសម្បទានសង្គមកិច្ច, ៧. ការជ្រើសរើសអ្នកដែលត្រូវទទួលបានដីធ្លី, ៨. ផែនការពេញលេញសម្រាប់ដីសម្បទានសង្គមកិច្ច, ៩. ការរៀបចំទីតាំង និង ១០. ការចូលតាំងទីលំនៅ និងការអភិវឌ្ឍជនបទ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ សូមជម្រាបផងដែរថា÷ ទីតាំងដីគម្រោង LASED III ឃុំទីវីង ទទួលបានការអនុម័តផែនការប្រើប្រាស់ដីលម្អិតទីតាំងសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានឃុំទីវីង ពី **ឯកឧត្តមប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត** នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ ដែលមានដីលំនៅឋានចំនួន ៣២៥ឡូត៍ ស្មើនឹង ៣៩.០០០១ហិកតា, ដីកសិកម្មចំនួន ៣២៥ឡូត៍ ស្មើនឹង ៦៥០ហិកតា, ដីតំបន់រដ្ឋបាលផ្ទៃដីសរុប ២២.១០៣០ហិកតា, តំបន់បៃតងផ្ទៃដីសរុប ៣៨.៤៩៧៧ហិកតា, អាងស្តុកទឹកផ្ទៃដីសរុប ១៦.៩៧៧ហិកតា, ស្រះទឹកផ្ទៃដីសរុប ១៦.៥៦៥៦ហិកតា, អណ្តូងទឹកផ្ទៃដីសរុប ២.៣៥៥១ហិកតា (១៨អណ្តូង), ទំនប់ផ្ទៃដីសរុប ៦.២៥៩០ហិកតា, និងដីផ្លូវផ្ទៃដីសរុប ៧៩.៣៣៨៨ហិកតា ( សរុប១៧ខ្សែ ស្មើនឹង ៣១០៨៩ម៉ែត្រ។ រហូតមកដល់ពេលនេះ ក្រុមប្រឹក្សាឃុំទីវីង បានបញ្ចប់ដំណើរការជ្រើសរើសមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋានឃុំទីវីង តាមផែនការសកម្មភាពជំហានទី៧ ស្តីពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ច ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារគម្រោង LASED III ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក មន្ទីរ-អង្គភាពពាក់ព័ន្ធក្នុងខេត្ត និងបានរៀបចំពិធីចាប់ឆ្នោតជ្រើសរើសយកឡូត៍ដីលំនៅឋាន និង ឡូត៍ដីកសិកម្ម ជូនប្រជាពលរដ្ឋដែលជាមុខសញ្ញាអ្នកទទួលដីអាទិភាព សរុបចំនួន ៣៧៦គ្រួសារ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ នៅទីតាំងបរិវេណវត្តសិរីមង្គល ហៅ "វត្តកំពង់ថ្កា" ស្ថិតក្នុងភូមិកំពង់ថ្កា ឃុំគោល ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។ បច្ចុប្បន្ននេះ ទីតាំងដីគម្រោង ឃុំទីវីង គឺបានកំពុងឈូសសម្អាតដី ដាំបង្គោលព្រំ រៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបែងចែកឡូត៍ដីជូនមុខសញ្ញាអ្នកទទួលដីទាំង ៣៧៦គ្រួសារ ។

ចំពោះការផ្សព្វផ្សាយព័ត៌មានរបស់ហ្វេសបុកផេកឈ្មោះ Horn News នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ ដែលបានលើកឡើងជាខ្លឹមសារថា "ប្រជាពលរដ្ឋបានលើកឡើងថាឈូសឆាយដីដំណាំរបស់គាត់យកទៅចែកឱ្យអ្នកផ្សេងធ្វើឱ្យគាត់មិនអាចទទួលយកបាននោះទេ អ្វីដែលប្រជាពលរដ្ឋឆ្ងល់ថាក្នុងក្រសួងដែនដីដែលប្រកាសគឺនៅឃុំគោល និង ឃុំទំរីងស្រុកសណ្ដាន់ ខេត្តកំពង់ធំ ហេតុអ្វីមកឈូសឆាយដីដំណាំប្រជាពលរដ្ឋនៅភូមិថ្មី ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំទៅវិញ" គឺជាការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវផ្ទុយពីការពិតទាំងស្រុង ដោយគ្មានការសិក្សាស្វែងយល់ពីការអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាល ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន និងបណ្ដាញសារព័ត៌មានទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

ថ្ងៃសុក្រ ១៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៥